# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីអំពី
## ជំហរ និងអនុសាសន៍ដើម្បីឯកភាពជាតិ និងការដោះស្រាយបញ្ហាជាតិ

ភ្នំពេញ, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជាយល់ឃើញថា គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ត្រូវការពេលវេលាសម្រាប់ការពិភាក្សាលើការស្វែងរកការពិតនៃភាពមិនប្រក្រតីនៃការបោះឆ្នោត និងកម្មវិធីកំណែទម្រង់ប្រព័ន្ធបោះឆ្នោត និងស្ថាប័នជាតិ។ មួយវិញទៀតពេលវេលា៦០ថ្ងៃក្រោយពីថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ នៅសល់រយៈពេលវែងនៅឡើយ ដូច្នេះការប្រជុំរដ្ឋសភាដំបូងគួរត្រូវបានធ្វើឡើងបន្ទាប់ពីគណបក្សទាំងពីរព្រមព្រៀងគ្នា ដើម្បីដោះស្រាយបញ្ហាជាតិ និងឈានទៅរកឯកភាពជាតិ។ មុននឹងឈានដល់ការកែទម្រង់លក្ខខណ្ឌចាំបាច់ ដំបូងគឺត្រូវមានការព្រមព្រៀងក្នុងការស្វែងរកការពិតនៃភាពមិនប្រក្រតីនៃការបោះឆ្នោតសិន ព្រោះថាការស្វែងរកការពិតនេះអាចធ្វើឲ្យម្ចាស់ឆ្នោតស្ងប់ចិត្ត និងមានទំនុកចិត្តលើការបោះឆ្នោត និងធ្វើឲ្យគណបក្សឈ្នះឆ្នោតទទួលបានកិត្តិយស។ លទ្ធផលបានមកពីការស្វែងរកការពិតនេះនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់កំណែទម្រង់ប្រព័ន្ធបោះឆ្នោត។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមធ្វើអនុសាសន៍ដូចខាងក្រោម៖

- គណបក្សទាំងពីរត្រូវតែបង្កើតគណៈកម្មការស្វែងរកការពិតទៅភាពមិនប្រក្រតីនៃការបោះឆ្នោត។ ក្នុងនោះត្រូវផ្តោតជាពិសេសទៅលើការសិក្សាស្រាវជ្រាវអំពីបញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់ ១១០២) ១១០៨ និងសន្លឹកឆ្នោតពីក្នុងកញ្ចប់សុវត្ថិភាព «ក» និងគល់បញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត។
- កំណែទម្រង់៖ កំណែទម្រង់នេះត្រូវឈរលើគោលការណ៍ត្រួតពិនិត្យ និងតុល្យភាពរវាងគណបក្សជាប់ឆ្នោតទាំងពីរ។ ក្រុមប្រឹក្សាកំណែទម្រង់មួយត្រូវបានបង្កើតឡើង ដែលមានសមាសភាពចេញពីតំណាងរាស្ត្រគណបក្សជាប់ឆ្នោតទាំងពីរ ដើម្បីដឹកនាំ និងត្រួតពិនិត្យមើលការអនុវត្តកំណែទម្រង់ទាំងនោះ។
- ពង្រឹងការត្រួតពិនិត្យអំណាចរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងក្នុងរដ្ឋសភា។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១.លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃ CHRAC | ០១២ ៩០ ១១ ៩៩ |
| ២.លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |
| ៣.លោក នី ចរិយា | ប្រធានស៊ើបអង្កេតនៃសមាគម ADHOC | ០១១ ២៧ ៤៩ ៥៩ |
| ៤.លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៥.លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | ០១២ ៩២ ៨៥ ៨៥ |
| ៦.លោក សឿង សារឿន | នាយកប្រតិបត្តិអង្គការ CCC | ០១៦ ៩០ ០៥ ០៣ |
| ៧.លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៨.លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ៩.លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១០.លោក យ៉ង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១១.លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧៧ ៨៣៣ |
| ១២.លោក ម៉ាក ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១៣.លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | ០១២ ៧៧ ៩៧ ៣៤ |
| ១៤.លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៥.លោក សាម អ៊ីន | នាយកប្រតិបត្តិ LWD | ០១២ ៥៥ ១៨ ៨៦ |
| ១៦.លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |